# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# ជំហរសង្គមស៊ីវិល ជុំវិញស្ថានភាពសិទ្ធិមនុស្សបច្ចុប្បន្ននៅកម្ពុជាពាក់ព័ន្ធការចាប់ឃុំខ្លួន បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ និងសកម្មជននយោបាយ

ភ្នំពេញថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៤

ក្រុមអង្គការសង្គមស៊ីវិល ជាអង្គការ-សមាគម ក្រៅរដ្ឋាភិបាលមិនធ្វើនយោបាយ និង មិនរកកម្រៃនៅក្នុងប្រទេសកម្ពុជា ចាត់ទុកថា សកម្មភាពរដ្ឋាភិបាលកម្ពុជាដែលបានចាប់និងឃុំខ្លួនបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្ររបស់គណបក្សសង្គ្រោះជាតិ គឺជាចេតនានយោបាយជាជាងការយកច្បាប់ទៅអនុវត្តន៍ឲ្យបានត្រឹមត្រូវ និងបានកំពុងធ្វើឲ្យការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននិងលទ្ធិប្រជាធិបតេយ្យ នៅកម្ពុជាដើរថយក្រោយ។

ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ដល់ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ យ៉ាងហោចសកម្មជនរបស់គណបក្សសង្គ្រោះជាតិ ចំនួន០៨នាក់ ត្រូវបានចាប់ និងឃុំខ្លួន ក្នុងនោះមាន០៧នាក់ ជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ និងម្នាក់ទៀតជាសកម្មជន។ ព័ត៌មានបានបង្ហាញថា នៅមានអញ្ញត្តិជនមួយចំនួនទៀតដែលកំពុងតាមស្វែងរកចាប់ខ្លួនផងដែរ។ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រទាំងនោះត្រូវបានគេដាក់ខ្នោះដៃទៅក្រោយ ហើយនាំយកទៅដាក់ពន្ធនាគារ នៅខណៈពេលដែលពួកគាត់ប្រើតួនាទីរបស់ខ្លួនក្នុងនាមជាតំណាងរាស្ត្រ ដោយគ្រាន់តែប្រើយន្តការសម្តែងមតិ ឬលើកយោបល់ស្នើសុំទាមទារឲ្យបើកទីលានប្រជាធិបតេយ្យ ដើម្បីឲ្យប្រជាពលរដ្ឋបានប្រើប្រាស់ឡើងវិញតែប៉ុណ្ណោះ។

ក្រុមអង្គការសង្គមស៊ីវិល មើលឃើញថា រាជរដ្ឋាភិបាលកម្ពុជា កំពុងគំរាមកំហែងការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបជុំ ដែលជាផ្នែកមួយដ៏សំខាន់នៃគោលការណ៍សិទ្ធិមនុស្សដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣១។ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងជួបប្រជុំគឺជាធាតុមួយដ៏សំខាន់ក្នុងប្រទេសដែលប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យដូចជាប្រទេសកម្ពុជានេះឯង។

ក្នុងនាមរដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយកម្ពុជាត្រូវតែអនុវត្តមាត្រា១៩ កថាខណ្ឌ២ ចែងថា «ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវព័ត៌មានទទួលនិងផ្សព្វផ្សាយព័ត៌មាន នឹងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែនដោយផ្ទាល់មាត់ឬបោះពុម្ពតាមទំរង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដ៏ទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន»។

អង្គការសង្គមស៊ីវិលយល់ឃើញថា ការគោរពសិទ្ធិមនុស្ស និង លំហរប្រជាធិបតេយ្យកាន់តែរួមតូចចង្អៀត ដែលជាការជះឥទ្ធិពលដល់សេរីភាពជាមូលដ្ឋានរបស់មនុស្ស ដូចជាការប្រើសេរីភាពបញ្ចេញមតិ និងសកម្មភាពជួបប្រជុំគ្នាជាដើម។ ជាងនេះទៅទៀតរាជរដ្ឋាភិបាលបាននិងកំពុងចេញបំរាមជាច្រើនដែលជាចេតនាទប់ស្កាត់រារាំង មិនឲ្យប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិសេរីភាពរបស់ពួកគេឲ្យបានពេញលេញ ប៉ុន្តែអំពើហិង្សាដែលកើតមានកន្លងមក ដូចជាព្រឹត្តិការណ៍នៅលើស្ពានស្ទឹងមានជ័យ ស្ពានអាកាសក្បាលថ្នល់ ផ្លូវវែងស្រេង និងរោងចក្រយ៉ាកជីងជាដើម អាជ្ញាធរកម្ពុជាខកខានក្នុងស្វែងរកជនប្រព្រឹត្តិមកផ្តន្ទាទោសតាមច្បាប់។ ជាមួយនោះដែរក្រុមសន្តិសុខស៊ីឈ្នួលរបស់ខណ្ឌដូនពេញ មិនតិចដងទេដែលបានវាយពលរដ្ឋ និងអ្នកកាសែតឲ្យរងរបួស ប៉ុន្តែអ្នកទាំងនោះ មិនត្រូវបានសមត្ថកិច្ចចាប់ខ្លួនមកផ្តន្ទាទោសតាមច្បាប់ឡើយ។

សេចក្តីប្រកាសព័ត៌មានថ្ងៃទី២៣ កញ្ញា ២០១៣ បានបញ្ជាក់ថា ក្នុងនាមជាព្រឹទ្ធបុរសនៃរដ្ឋសភាសម្តេចពញាចក្រី ហេង សំរិន បានប្រកាសផ្តល់សុពលភាពតំណាងរាស្ត្រ បេក្ខជនជាប់ឆ្នោត១២៣រូប ដូចនេះ ការចាប់ឃុំខ្លួនអ្នកទាំង ០៧ រូប នាពេលនេះ គឺរំលោភរដ្ឋធម្មនុញ្ញ មាត្រា ៨០ រដ្ឋធម្មនុញ្ញ (អំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ) ក្នុងសកម្មភាពសម្តែងមតិ លើកជាយោបល់ក្នុងការបំពេញមុខងាររបស់អ្នកតំណាងរាស្ត្រមិនមែនជាមូលហេតុនៃការចោទប្រកាន់ចាប់ខ្លួន ឬ ឃុំ ខ្លួនឡើយ។

អង្គការសង្គមស៊ីវិលសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា សូមដោះលែងបេក្ខជនជាប់ឆ្នោត តំណាងរាស្ត្រ ទាំងអស់ឲ្យមានសេរីភាពឡើងវិញជាបន្ទាន់ និងដោយគ្មានល័កខណ្ឌ និងសូមបញ្ឈប់ ការតាមចាប់ខ្លួនអ្នកពាក់ព័ន្ធដទៃទៀត និងសូមឲ្យមានការស៊ើបអង្កេតស្រាវជ្រាវជុំវិញបទល្មើសដែលបានកើតមានកន្លងមកព្រមទាំងស្នើឲ្យមានការបើកប្រើប្រាស់ទីលានប្រជាធិបតេយ្យឡើងវិញ។ ស្របពេលជាមួយគ្នានេះ អង្គការសង្គមស៊ីវិលសូមឲ្យគណបក្សនយោបាយជាប់ឆ្នោតទាំងពីរ បន្តការចរចាដោយឈរលើជំហាផលប្រយោជន៍ប្រជាជាតិជាធំ ដើម្បីដោះស្រាយវិបត្តិនយោបាយនាពេលបច្ចុប្បន្ន និងស្តារឡើងវិញនូវ ការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

**ពត៌មានបន្ថែមសូមទាក់ទង:**

| | | |
|---|---|---|
| -លោក នី ចរិយា | ប្រធានផ្នែកសិទ្ធិមនុស្ស និងច្បាប់ ADHOC | 011 27 49 59 |
| -លោក គល់ បញ្ញា | នាយកប្រតិបត្តិCOMFREL | 012 49 20 17 |
| -លោក សួន ប៊ុនស័ក្តិ | ប្រធានលេខាធិការដ្ឋាន CHRAC | 092 34 43 57 |
| -លោក យង់ គិមអេង | ប្រធាន PDP-Center | 016 82 82 11 |
| -លោក សៀ ភារម្យ | ប្រធានលេខាធិការដ្ឋាននៃ HRTF | 012 85 23 25 |

**ក្រុមអង្គការសង្គមស៊ីវិលគាំទ្រ:**

1. សមាគមអាដហុក (ADHOC)
2. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)
3. គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សនៅកម្ពុជា (CHRAC)
4. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum)
5. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
6. ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF)
7. អង្គការ និចហ្វិក
8. សម្ព័ន្ធសហគមន៍កសិករកម្ពុជា CCFC
9. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា CICA
10. បណ្តាញយុវជនកម្ពុជា CYN
11. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋក្រៅប្រពន្ធ IDEA
12. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្ម CFSWF
13. អង្គការ KYSD
14. អង្គការ YRDP
15. សមាគមយុវជនខ្មែរ KYA
16. អង្គការខារ៉ាមកម្ពុជា (CARAM Cambodia)
17. សមាគមឥន្ទ្រទេវី (IDA)
18. មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
19. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
20. អង្គការ GADC
21. អង្គការ CDP
22. អង្គការ PDP
23. អង្គការ KKKHRDA
24. អង្គការ LAC
25. អង្គការ CWCC
26. អង្គការ VIGILANCE
27. អង្គការ PJJ
28. អង្គការ GENEROUS
29. អង្គការ CHHRA